# ជំពូក ៧

## ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

## Environmental Management Plan

Draft

# ជំពូកទី ៧

## ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

### ៧.១ សេចក្តីផ្តើម

នៅក្នុងជំពូកនេះគឺ រៀបរាប់អំពីផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) ដែលនឹងត្រូវអនុវត្តតាមដំណាក់កាលរបស់គំរោង ជា ពិសេសក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិថែទាំគំរោង និងបញ្ចប់គំរោង ។ គោលបំណងសំខាន់នៃ ផ.គ.ប នេះគឺត្រួតពិនិត្យ តាមដាននូវការអនុវត្តនីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូកទី ៥ ។

ការអនុវត្តនី ផ.គ.ប នេះជាភារកិច្ចរបស់ក្រុមចំរុះ ដែលមានការចូលរួមពីការិយាល័យ , មន្ទីរ , ក្រសួងដែលពាក់ព័ន្ធ ដែលនឹងត្រូវបង្កើតឡើងដោយម្ចាស់គំរោងរួមជាមួយក្រសួងបរិស្ថាន ។ ក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការការពារ បរិស្ថាននេះ និងក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងបរិស្ថាន ។

### ៧.២ សមាសភាពនៃក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការការពារបរិស្ថាន

សមាសភាពក្រុមត្រួតពិនិត្យនេះ ជាអ្នកធ្វើការងារមានសមាជិកចំរុះមកពីស្ថាប័នពាក់ព័ន្ធដូចតទៅ :

១- ក្រសួងបរិស្ថាន រួមមាន មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន, មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន, និងនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង

២- មន្ត្រីជំនាញតំណាងឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៣- មន្ត្រីជំនាញតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤- មន្ត្រីជំនាញតំណាងឱ្យរដ្ឋបាលព្រៃឈើ

៥- មន្ត្រីជំនាញតំណាងឱ្យមន្ទីរបរិស្ថាន ខេត្តកោះកុង

៦- មន្ត្រីជំនាញតំណាងឱ្យមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកោះកុង

៧- មន្ត្រីជំនាញតំណាងឱ្យមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកោះកុង

៨- មន្ត្រីជំនាញតំណាងឱ្យមន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ខេត្តកោះកុង

៩- មន្ត្រីជំនាញតំណាងឱ្យក្រសួង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សុរិយោដី និងសំណង់ ខេត្តកោះកុង

១០- មន្ត្រីជំនាញតំណាងឱ្យមន្ទីរសាធារណការ ខេត្តកោះកុង

១១- មន្ត្រីជំនាញតំណាងឱ្យមន្ទីរសុខាភិបាល ខេត្តកោះកុង

១២- មន្ត្រីជំនាញតំណាងឱ្យមន្ទីរទេសចរណ៍ ខេត្តកោះកុង

១៣- អាជ្ញាធរដែនដី

១៤- អ្នកតំណាងឱ្យក្រុមហ៊ុន ។

សមាសភាពក្រុមខាងលើមានតួនាទីពិនិត្យតាមដានដោយផ្ទាល់ និងដោយប្រយោល ដើម្បីជួយតំរែតំរង់ និងកែលំអរ រាល់កាខ្វះខាតរបស់ក្រុមហ៊ុនក្នុងការអនុវត្តនីវិធានការការពារបរិស្ថានរបស់គំរោង ។

<u>បញ្ជាក់:</u> សមាសភាពមន្ត្រីទាំងអស់នេះ នឹងត្រូវផ្តល់តួនាទី និងមុខងារក្រោមការចង្អុលបង្ហាញពីក្រសួងបរិស្ថាន ។

Draft

## ៧.៣ វិធានការសំខាន់ៗសម្រាប់ការពារបរិស្ថាន

យោងតាមអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង យោងតាមលទ្ធផលនៃការសិក្សា ការវាយតំលៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គំរោង ដូចបានរៀបរាប់នៅក្នុងជំពូកទី ៥ ម្ចាស់គំរោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួនសម្រាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះ ដោយប្រសិទ្ធិភាពស្របទៅតាមលក្ខណៈបច្ចេកទេស និង បទដ្ឋានបរិស្ថានព្រមទាំងធានាឱ្យគំរោងអភិវឌ្ឍន៍ប្រកបដោយស្ថេរភាពដែលក្នុងនោះរួមមាន :

- ការរៀបចំផ្នែក ឬ ក្រុមទទួលខុសត្រូវសម្រាប់ការអនុវត្តន៍ផែនការការងារ ។
- កំណត់ពេលវេលាធ្វើការងារឱ្យច្បាស់លាស់ ក្នុងកិច្ចការការពារបរិស្ថាន ។
- បំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស ។
- ការពារ និងបង្ការជំងឺរាតត្បាតផ្សេងៗ ។
- ការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់សារធាតុពុល ។
- ការធ្វើកន្លែងទុកសំណល់រឹង ។
- ជំរុញឱ្យមានការដាំដើមឈើ នៅទីសាធារណៈ ឬតំបន់ជុំវិញតំបន់ការពារទាំងនោះ ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងបច្ចេកទេស និងទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតម្រូវឱ្យធ្វើ ។
- ធ្វើការអភិរក្ស ប្រភេទសត្វព្រៃសំខាន់ៗដែលធ្លាប់មាននៅតំបន់គំរោង ។
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីប្រភេទព្រៃឈើ និងពពួកសត្វព្រៃ ដែលត្រូវអភិរក្សក្នុងតំបន់គំរោង ។
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំ វិធីសាស្ត្រការពារសុខភាព អនាម័យ-សុវត្ថិភាពការងារ ។
- ត្រៀមថវិកាបំរុងទុកសម្រាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន ។

<u>**បញ្ជាក់:**</u> ក្រុមហ៊ុននឹងត្រៀមថវិកាចំនួន US$២.៩៥៦.២០៦,០០ (ពីរលានប្រាំសែនប្រាំមុឺនប្រាំមួយពាន់ពីររយប្រាំមួយដុល្លាអាមេរិក) សំរាប់ការការពារបរិស្ថាននៅក្នុងដំណាក់កាលសាងសង់គំរោង។ ជាងនេះទៅទៀតក្រុមហ៊ុន នឹងត្រៀមប្រាក់ US$ ៧៧.០០០,០០ (ប្រាំពីរមុឺនប្រាំពីរពាន់ដុល្លាអាមេរិច) ក្នុងមួយឆ្នាំៗ សំរាប់ការការពារបរិស្ថាន ហើយដែលមានតំលៃសរុប US$ ៣.០៨០.០០០,០០ (បីលានប្រាំបីមុឺនដុល្លាអាមេរិច)នៅក្នុងដំណាក់ការប្រតិបត្តិគំរោងរយៈពេល៤០ឆ្នាំ។

## ៧.៤ កម្មវិធីអង្កេតតាមដាន ត្រួតពិនិត្យការអនុវត្តន៍វិធានការការពារបរិស្ថាន

កម្មវិធីអង្កេតតាមដាន ត្រួតពិនិត្យការអនុវត្តន៍វិធានការការពារបរិស្ថាន (វិធានការកាត់បន្ថយការប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូក ៥ ចំណុចលេខ ៥.២ ឬក្នុងកំណត់ទំហំនៃការប៉ះពាល់អវិជ្ជមាន និង វិធានការកាត់បន្ថយ) នេះ និងបញ្ជាក់អំពីកិច្ចការដែលត្រូវអង្កេតតាមដាន និងត្រួតពិនិត្យគំរោងផងដែរ ។ម៉្យាងវិញទៀតកម្មវិធីនេះនឹងប្រមើលឃ្លាំមើលសកម្មភាពការអនុវត្តន៍គំរោង ដោយម្ចាស់គំរោងនៅក្នុងគ្រប់ដំណាក់កាលគំរោង ។ កម្មវិធីនេះមានដូចតទៅ: (មានចែងក្នុងតារាងលេខ ៤០ ខាងក្រោម)

## តារាងលេខ៤០ : ផែនការត្រួតពិនិត្យតាមដានបរិស្ថាន

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន | អ្នកត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| • បរិស្ថានរូបសាស្ត្រ | | | | |
| ១ | សណ្ឋានដី និង ឋានលេខា | - ពិនិត្យមើលការឈូសឆាយភ្នំកន្លែងយកថ្មតើបានធ្វើដើងទេត្រឹមត្រូវ ដាំស្មៅ ឬចាក់បេតុង ការពារការហូរ ច្រោះឬទេ និង ត្រួតពិនិត្យការពង្រាបដី ។<br>- ត្រួតពិនិត្យការពង្រាបដី នៅការដ្ឋានយកដី ថ្ម គ្រួស កន្លែងចោលដីស្អុយ ពេលសាងសង់រួចមាន សំអាតធ្វើដើងទេជញ្ជាំង និងដាំដើមឈើឡើងវិញនៅកន្លែងទាំងនោះ ។ | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តគំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង ។ |
| ២ | ការហូរច្រោះ និង គុណភាពដី | - ពិនិត្យមើលការឈូសឆាយភ្នំ តើបានធ្វើដើងទេ ត្រឹមត្រូវ ដាំស្មៅ ឬចាក់បេតុង ការពារការហូរ ច្រោះឬទេ តាមជញ្ជាំងទំនប់ និង ប្រឡាយ ។<br>- ពិនិត្យមើលគុណភាពដីនៅខាងកន្លែងស្តុកសំភារៈ ស្តុកប្រេងឥន្ធនៈ សារធាតុគីមី រោងជាង មានការសំអាត និង គ្រប់គ្រងត្រឹមត្រូវល្អ ឬទេ ។<br>- ពិនិត្យមើលការដាំកំរាលរុក្ខជាតិ ការពារការហូរច្រោះដី នៅកន្លែងចោលដីស្អុយ កន្លែងយកដី ថ្ម គ្រួស និង ខ្សាច់ ។<br>- ពិនិត្យមើលកន្លែងចតគ្រឿងចក្រនិង កន្លែងស្តុក ប្រេង និង( ការកំពុបសារធាតុទាំងនេះលើដី) ។ | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន | អ្នកត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៣ | ប្រពន្ធ័ជលសាស្ត្រ | - សង្កេត តាមដានមើលភាពប្រែប្រួលនៃស្ទឹង ព្រែក អូរនៅក្នុងតំបន់គំរោងទាំងមូល.<br>- ត្រួតពិនិត្យមើលការបញ្ចេញទឹកទៅខាងក្រោមអាង Site A មានចំនួន ១,៥ម³/វិនាទី មកខាងក្រោមដើម្បីការពារជីវៈចំរុះនៃកំណាត់ស្ទឹងនៅចន្លោះទំនប់ និងអគារថាមពល ។<br>- ត្រួតពិនិត្យប្រព័ន្ធលូរទឹកស្អុយដែលបង្ហូរចូលក្នុងអូរ ស្ទឹង (យកទឹកទៅវិភាគនៅកន្លែងចំណុចប្រសព្វមាត់ហូរចេញពីអូរទៅស្ទឹងជាយអាវែងរួចពិនិត្យលទ្ធផល យោងតាមស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសម្រាប់រក្សាជីវៈចំរុះរបស់ក្រសួងបរិស្ថាន ឬទេ) ។<br>- បង្កើតស្ថានីយ៍ជលសាស្ត្រ ៤ កន្លែងនៅក្នុងអាង នៅខាងក្រោមទំនប់ ២០០ ម នៅខាងក្រោមអគារថាមពល ៣០០ ម និងនៅព្រែកត្រពាំងរូង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹក និងឧតុនិយម | - ក្នុងពេលចាប់ផ្តើមអនុវត្តគំរោងត្រូវធ្វើម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង់និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំរយៈពេល ៣ ខែម្តង។ |
| ៤ | គុណភាពទឹកក្រោមដី និង លើដី | - ពិនិត្យមើលបំរែបំរួលកំរិតកំពស់ទឹកក្រោមដីនៅក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យកាកសំណល់រឹងរាវកន្លែងរស់នៅ និងការិយាល័យរបស់គំរោង និង ពិនិត្យមើលកន្លែងចតគ្រឿងចក្រនិងកន្លែងស្តុកប្រេង និងសារធាតុគីមី ( ការកំពុបសារធាតុទាំងនេះ) ។ មានការលេចជ្រាបចូលប្រភពទឹកក្រោមដីដែរឬទេ?<br>- ពិនិត្យមើលគុណភាពទឹកតាមរយៈពិសោធន៍គុណភាពស្ទឹងជាយអាវែងដោយបញ្ជាក់ថា គុណភាពយោងតាមស្តង់ដាគុណភាពទឹក ក្នុងប្រភពទឹកសាធារណៈសម្រាប់រក្សាជីវៈចំរុះរបស់ក្រសួងបរិស្ថាន ។ | | |



Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន | អ្នកត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៥ | ធនធានព្រៃឈើ និង ជីវកសត្វ | - ត្រួតពិនិត្យមើលសកម្មភាពបរបាញ់សត្វ និង ចរាចរ ឈើ និង សត្វព្រៃរបស់បុគ្គលិក កម្មករ គំរោង ។<br>- ត្រួតពិនិត្យសំលេងរបស់គ្រឿងចក្រ និង ពេលវេលាធ្វើការ ។ | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ<br>- អាជ្ញាធរដែនដី<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - ក្នុងពេលចាប់ផ្តើមអនុវត្តគំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង។ |
| ៦ | ជីវសាស្ត្រ សត្វព្រៃ និង មច្ឆជាតិ | - ត្រួតពិនិត្យមើលសកម្មភាពបរបាញ់សត្វរបស់បុគ្គលិក គំរោង ។<br>- ត្រួតពិនិត្យសំលេងរបស់គ្រឿងចក្រ និង ពេលវេលាធ្វើការ ។<br>- ត្រួតពិនិត្យ តាមដានប្រភេទ និងបរិមាណសត្វព្រៃ ត្រី ។ | | |
| ៧ | ការបំពុលខ្យល់ | - ត្រួតពិនិត្យមើលគុណភាពខ្យល់ក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យមើលការបញ្ចេញផ្សែងរបស់គ្រឿងចក្រ ។<br>- ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់ គំរោងមានភាយក្លិនមិនល្អឬទេ ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>- រដ្ឋបាលព្រៃឈើ | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈ ពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិនិងថែទាំ គំរោង រយៈពេល ៣ខែម្តង ។ |
| ៨ | ការបំពុលទឹក | - ត្រួតពិនិត្យព្រៃឈើកន្លែងដែលត្រូវលិច (មើលផែនទីទី២) បានកាប់សំអាតឬទេ មុនពេលដក់ទឹកក្នុងអាង ។<br>- ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់គំរោង ។<br>- ត្រួតពិនិត្យប្រព័ន្ធលូរទឹកស្អុយដែលបង្ហូរចូលក្នុងអូរ ព្រែក (យកទឹកទៅវិភាគនៅ កន្លែងចំណុចប្រសព្វ មាត់ហូរចេញពីអូរ ទៅស្ទឹងជាយអាវែងរួចពិនិត្យលទ្ធផល យោងតាមស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសម្រាប់រក្សាជីវៈចំរុះរបស់ ក្រសួងបរិស្ថាន ឬទេ ) ។ | | |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន | អ្នកត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៩ | ការបំពុលដី | - ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់គំរោង ។<br>- ត្រួតពិនិត្យកន្លែងស្តុកប្រេងឥន្ធនៈ កន្លែងចតគ្រឿងចក្ររបស់គំរោង (ការកំពុបប្រេង និង ថ្នាំគីមីទៅ លើដី) ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- រដ្ឋបាលព្រៃឈើ | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិនិងថែទាំគំរោង រយៈពេល ៣ខែម្តង ។ |
| ១០ | សំលេង និង រំញ័រ | - ត្រួតពិនិត្យសំលេង និង រំញ័ររបស់រថយន្ត គ្រឿងចក្រ ក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យពេលវេលាធ្វើការរបស់គំរោង ។ | | |
| • បរិស្ថានសង្គម | | | | |
| ១ | ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ | - ត្រួតពិនិត្យមើលផែនការតាំងទីលំនៅឡើងវិញរបស់គំរោង ។<br>- ត្រួតពិនិត្យមើលការដោះស្រាយទំនាស់ដីធ្លី ។<br>- ត្រួតពិនិត្យមើលការដោះស្រាយទូទាត់សំណងចំពោះដីដែលកាន់កាប់ស្របច្បាប់ ហើយត្រូវបាត់បង់ដោយសារគំរោង ។ | - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- អាជ្ញាធរដែនដី | - ក្នុងពេលចាប់ផ្តើមអនុវត្តគំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល ៣ខែម្តង ដល់បញ្ចប់ការតាំងលំនៅដ្ឋានឡើងវិញ (រយៈពេល៣ឆ្នាំ) ។ |
| ២ | ការរស់នៅ និងមុខរបររបស់សហគមន៍ មូលដ្ឋាន | - ត្រួតពិនិត្យការជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុន (ផ្តល់អាទិភាពឱ្យអ្នកភូមិក្នុងតំបន់) ។<br>- ត្រួតពិនិត្យលើការស្តារឡើងវិញនូវកម្មវិធីរកចំណូលរបស់អ្នកប៉ះពាល់ (ដូចមានចែងក្នុង ផែការតាំងទីលំនៅឡើងវិញ) ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- អាជ្ញាធរដែនដី | - ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំគំរោង រយៈពេល ៣ខែម្តង ។ |
| ៣ | ប្រពៃណី វប្បធម៌ និងសាសនា | - ពិនិត្យតាមដានរាល់ការខុសឆ្គង និងអំពើល្មើសរបស់បុគ្គលិករបស់ក្រុមហ៊ុន ទៅលើប្រពៃណី ទំនៀមទំលាប់ និងវប្បធម៌របស់ប្រទេសជាតិ និងរបស់ប្រជាជនមូលដ្ឋាន ។ | | |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន | អ្នកត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៤ | ផ្លូវគមនាគមន៍ និងចរាចរ | - ត្រួតពិនិត្យការធ្វើចរាចរណ៍ និងផ្លាកសញ្ញាល្បឿន តាមផ្លូវក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការថែទាំជួសជុលផ្លូវក្នុងតំបន់គំរោង ។<br>- ពិនិត្យការថែទាំផ្លូវតំបន់ទេសចរណ៍ថ្មី ក្នុងតំបន់អាងជាយអារែង ឬតំបន់ក្បែរខាង (ប្រសិនបើមាន) ។<br>- ត្រួតពិនិត្យសំលេង និង រំញ័ររបស់រថយន្ត គ្រឿងចក្រ ក្នុងតំបន់គំរោង ។ | - ក្រសួងបរិស្ថាន<br>- មន្ទីរសាធារណការខេត្តកោះកុង<br>- មន្ទីរទេសចរណ៍ខេត្ត<br>- អាជ្ញាធរដែនដី | - ក្នុងពេលចាប់ផ្តើមអនុវត្តគំរោងរយះពេល ៣ខែម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយះពេល ៣ ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំគំរោងរយះពេល ៣ខែម្តង ។ |
| ៥ | សុខភាពសាធារណៈ | - ត្រួតពិនិត្យការថែរក្សាសុវត្ថិភាពនៅក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការថែទាំសុខភាពរបស់បុគ្គលិកកម្មករគំរោង ។<br>- ត្រួតពិនិត្យមើលបរិក្ខា និងថ្នាំពេទ្យ ។<br>- ត្រួតពិនិត្យលើការទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការធ្វើចរាចរ និង ផ្លាកសញ្ញាល្បឿន តាមផ្លូវក្នុងតំបន់គំរោង ។ | - ក្រសួងបរិស្ថាន<br>- មន្ទីរសុខាភិបាលខេត្តកោះកុង<br>- អាជ្ញាធរដែនដី<br>- មន្ទីរសាធារណការខេត្តកោះកុង | |
| ៦ | ហានិភ័យ | - ពិនិត្យតាមដានរាល់ហេតុការណ៍ ដែលអាចឱ្យមានការបាក់ទំនប់ បាក់ភ្នំ ។<br>- ត្រួតពិនិត្យការថែរក្សា សន្តិសុខ និង សុវត្ថិភាព លើជាតិផ្ទុះ ជាតិឆេះ ។<br>- ពិនិត្យ និងទប់ស្កាត់ភ្លើងឆេះព្រៃ និងអំពើភាវរកម្ម ក្នុងតំបន់គំរោង ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ<br>- អាជ្ញាធរមូលដ្ឋាន | - ក្នុងអំឡុងពេលសាងសង់គំរោង រយះពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំគំរោងរយះពេល៣ខែម្តង ។ |

Draft

## ៧.៥ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបំពាក់បំប៉នក៏ជាកត្តាសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ ដែលគំរោងត្រូវយកចិត្តទុកដាក់ ដើម្បីអនុវត្តផែនការរបស់គំរោងឱ្យបានជោគជ័យ ។ ដើម្បីធ្វើឱ្យគំរោងនេះ មានការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាពចាំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារឱ្យបានរីកចំរើន និងសុក្រឹត្យត្រឹមត្រូវទាំងការងារបច្ចេកទេស និង ការងារបរិស្ថាន ដូច្នេះម្ចាស់គំរោងនឹងរៀបចំឱ្យមានវគ្គអប់រំបំពាក់បំប៉នដល់បុគ្គលិក និងកម្មករមានដូចជា :

- ចំណេះដឹងបច្ចេកទេសសម្រាប់ប្រើ ឬបញ្ជាគ្រឿងម៉ាស៊ីនគ្រប់ប្រភេទក្នុងពេលសាងសង់ និងដំណើរការគំរោង ។
- ចំណេះដឹងពីការការពារសុវត្ថិភាពជាចំបង ពេលកំពុងបំពេញការងាររបស់គំរោង ។
- បំពាក់បំប៉ន និង ផ្សព្វផ្សាយពីជំនាញបច្ចេកទេសច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធ ការបង្កឱ្យមានគ្រោះថ្នាក់ជាយថាហេតុពីសកម្មភាពគំរោងទៅលើធនធានធម្មជាតិ និងសង្គម ។
- អប់រំ និងផ្សព្វផ្សាយវិធីសាស្ត្រការពារជំងឺរាតត្បាតផ្សេងៗ ជាពិសេសជំងឺអេសដីជាដើម ។
- បំពាក់បំប៉នដល់កម្មករក្នុងការគ្រប់គ្រងសំណល់រឹង-រាវ និងអប់រំបំពាក់បំប៉នបុគ្គលិកក្នុងការប្រើប្រាស់ និងថែទាំប្រព័ន្ធអាងប្រព្រឹត្តិកម្ម សំណល់រាវ ។
- អប់រំពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗ ដែលមាននៅក្នុងតំបន់សម្រាប់តម្រូវការសង្គម ដូចជា ទឹក ដី ខ្យល់ ព្រៃឈើ សត្វព្រៃ ជាពិសេសធនធានធម្មជាតិនៃតំបន់អភិរក្សភ្នំក្រវាញទាំងនោះ ។ល។
- អប់រំពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង-ជុំវិញតំបន់គំរោង និងចំណេះដឹងពីការអង្កេតតាមដានគំរោងដែលទាក់ទងទៅនឹងបរិមាណ និងគុណភាពបរិស្ថានមានស្រាប់ ដែលនឹងត្រូវរងការប៉ះពាល់ដោយសារសកម្មភាពគំរោងនេះ ។
- អប់រំដល់កម្មករក្នុងការគ្រប់គ្រងវត្ថុធាតុដើមដែលជាសារធាតុគីមីសម្រាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតកម្មរបស់គំរោង ។
- ការបំពាក់បំប៉នទាំងនេះក្រុមហ៊ុននឹងទទួលបន្ទុកចំណាយទាំងស្រុង មិនតែប៉ុណ្ណោះ ក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពខ្ពស់នៅប្រទេសចិន ហើយក្រុមហ៊ុននឹងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងប្រទេសចិន និងកម្ពុជា ដោយបញ្ជូនគណៈប្រតិភូទៅទស្សនៈកិច្ចសិក្សានៅប្រទេសចិន ដែលខ្លួនបានធ្វើវារីអគ្គិសនីកន្លងមក ដើម្បីដកស្រង់យកបទពិសោធន៍ជាកំរិតអន្តរជាតិ ។

## ៧.៦ ការប៉ាន់ប្រមាណថវិកាសម្រាប់កិច្ចការពារបរិស្ថាន

ក្រុមហ៊ុននឹងត្រៀមថវិកាចំនួន US$ ២.៥៥៦.២០៦,០០ (ពីរលានប្រាំសែនប្រាំម៉ឺនប្រាំមួយពាន់ពីររយប្រាំមួយដុល្លាអាមេរិក) សំរាប់ការការពារបរិស្ថាននៅក្នុងដំណាក់កាលសាងសង់គំរោង។ ជាងនេះទៅទៀតក្រុមហ៊ុន នឹងត្រៀមប្រាក់ US$ ៧៧.០០០,០០ (ប្រាំពីរម៉ឺនប្រាំពីរពាន់ដុល្លាអាមេរិច) ក្នុងមួយឆ្នាំៗ សំរាប់ការការពារបរិស្ថាន ហើយដែលមានតំលៃសរុប US$ ៣.០៨០.០០០,០០ (បីលានប្រាំបីម៉ឺនដុល្លាអាមេរិច) នៅក្នុងដំណាក់ការប្រតិបត្តិគំរោងរយៈពេល៤០ឆ្នាំ ។ ថវិការសំរាប់ការការពារបរិស្ថាននៅក្នុងផ្នែកខាងលើនេះខុសពីថវិការសំណួមពរដោយCI ពីព្រោះការប៉ាន់ស្មានថវិការសំរាប់កាការពារបរិស្ថាននៅក្នុងផ្នែកនេះគឺគិតបញ្ចូលថវិការមួយផ្នែកដែលលើកឡើងដោយCI និងជាពិសេសយោងទៅតាមស្ថានភាពជាក់ស្តែងនៃលក្ខណៈរបស់គំរោង នៅក្នុងនោះថវិការដែលលើកឡើងដោយCI គឺប្រើសំរាប់ការការពាររុក្ខជាតិ និងសត្វព្រៃ តែថវិការដែលលើកឡើងខាងលើនិងប្រើដើម្បីការការពារ ធនធានរូបសាស្ត្រ ជីវសាស្ត្រ សង្គម និង សេដ្ឋកិច្ច ។



Draft